ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិ
រៀបចំបុណ្យជាតិ-អន្តរជាតិ
លេខៈ ០៧៥/២០២៥ គ.ជ.ប.អ.

# ផែនការណែនាំ
## ស្តីពី
## ការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យខួបលើកទី២១ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ ថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

**<u>យោង</u>** :-ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១២០៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-អនុក្រឹត្យលេខ ២០៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០២៥

-សារាចរណែនាំ សម្រាប់អនុវត្តជាអចិន្ត្រៃយ៍ លេខ ០៩ សរណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទាំងសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ

ឆ្នាំនេះ ព្រះរាជពិធីបុណ្យខួបលើកទី២១ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ ថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានក្រុមប្រឹក្សារាជសម្បត្តិបោះឆ្នោតជ្រើសរើសជាឯកច្ឆន្ទ នាថ្ងៃព្រហស្បតិ៍ ១កើត ខែអស្សុជ ឆ្នាំវក ឆស័ក ព.ស.២៥៤៨ ត្រូវនឹងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៤ ជា **ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះគោរមងារ "**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**" ហើយសម្រេចយក ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤ ជាទិវាប្រវត្តិសាស្ត្រនៃការគ្រងព្រះបរមសិរីរាជសម្បត្តិ។ គឺថ្ងៃនេះហើយដែលប្រជារាស្ត្រខ្មែរគ្រប់រូប បានសម្តែងឆន្ទៈ និងមនោសញ្ចេតនារបស់ខ្លួនសប្បាយរីករាយយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គសព្វព្រះរាជហឫទ័យទ្រង់គ្រងព្រះបរមសិរីរាជសម្បត្តិ ដើម្បីបានគង់ជាម្លប់ដ៏សុខក្សេមក្សាន្ត ត្រជាក់ត្រជុំរបស់មាតុភូមិ និងប្រជារាស្ត្ររបស់ព្រះអង្គ។



វិថីឧកញ៉ា ឈុន កែងវិថីព្រះស៊ីសុវត្ថិ ទល់មុខសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ E-mail: nconif@gmail.com Phone: 012 912 265 / 097 97 69 111

ដើម្បីសម្តែងនូវកតញ្ញុតាធម៌ និងថ្វាយព្រះរាជសព្ទសាធុការពរ បវរមហាប្រសើរថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលទ្រង់ប្រកបដោយព្រះបញ្ញាញាណ និងព្រះរាជហឫទ័យសន្តោសដ៏ថ្លៃថ្លា សូមទ្រង់គង់នៅក្នុងព្រះបរមសិរីរាជសម្បត្តិយូរអង្វែង គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សូមធ្វើការណែនាំដូចតទៅ ៖

* <u>ក្រសួងព្រះបរមរាជវាំង</u>

រៀបចំព្រះរាជពិធីបុណ្យខួបលើកទី២១ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិថ្វាយ **ព្រះមហាក្សត្រ** នៅក្នុងព្រះបរមរាជវាំង តាមព្រះរាជប្បវេណី និងប្រពៃណីសាសនា តាមការសព្វព្រះរាជហឫទ័យរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

* <u>គ្រប់ក្រសួង ស្ថាប័ន និងស្ថាប័ន</u>

រៀបចំតាំងព្រះបរមឆាយាល័ក្ខណ៍ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ដោយមានតុបតែងលម្អបំភ្លឺភ្លើងពណ៌ ពាក្យស្លោកថ្វាយព្រះពរ និងសារលិខិតថ្វាយព្រះពរ ព្រមទាំងលើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក នៅតាមក្រសួង ស្ថាប័ន និងស្ថាប័នរបស់ខ្លួន។

* <u>រដ្ឋបាលរាជធានី ខេត្ត</u>

-រៀបចំព្រះរាជពិធីបុណ្យខួបលើកទី២១ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ឱ្យបានស័ក្តិសមក្នុងក្របខ័ណ្ឌរាជធានី ខេត្ត។

-រៀបចំតាំងព្រះបរមឆាយាល័ក្ខណ៍ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ដោយមានតុបតែងលម្អបំភ្លឺភ្លើងពណ៌ លើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក មានសារលិខិតថ្វាយព្រះពរ និងណែនាំមន្ទីរ អង្គភាព ក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថានសាធារណៈ សាលារៀន ឱ្យតុបតែងលម្អ បំភ្លឺភ្លើងពណ៌ លើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក និងបំផុសប្រជាពលរដ្ឋឱ្យលើកទង់ជាតិគ្រប់គេហដ្ឋាន ព្រមទាំងរៀបចំឱ្យមានកម្មវិធីចុះសួរសុខទុក្ខអ្នកជំងឺ តាមមន្ទីរពេទ្យបង្អែក កុមារកំព្រា ជនពិការ និងចាស់ជរាគ្មានទីពឹង។

* <u>ក្រសួងធម្មការ និងសាសនា</u>

ណែនាំមន្ទីរធម្មការ និងសាសនា រាជធានី ខេត្ត រម្លឹកគ្រប់វត្តអារាមឱ្យរៀបចំព្រះរាជពិធីគ្រងព្រះបរមសិរីរាជសម្បត្តិថ្វាយព្រះរាជកុសល និងព្រះរាជសព្ទសាធុការពរថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដោយរៀបចំតាំងព្រះបរមឆាយាល័ក្ខណ៍ ដោយមានតុបតែងលម្អបំភ្លឺភ្លើងពណ៌ លើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោកឱ្យបានសមរម្យ។

* <u>ក្រសួងព័ត៌មាន</u>

ណែនាំឱ្យបណ្តាញឃោសនា វិទ្យុ ទូរទស្សន៍ជាតិ និងឯកជន តាមដានយកព័ត៌មាន ធ្វើការផលិតផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវព្រះរាជជីវប្រវត្តិ ព្រះរាជសកម្មភាព និងស្នាព្រះហស្ត **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

*** ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

ណែនាំដល់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រាជធានី ខេត្ត រៀបចំក្រុមតន្ត្រីសិល្បៈ និងចម្រៀងបុរាណសម័យ សម្ដែង និងប្រគំជូនប្រជាពលរដ្ឋទស្សនាកម្សាន្តសប្បាយរីករាយ នៅតាមទីសាធារណៈ នាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥ ដើម្បីចូលរួមអបអរសាទរក្នុងទិវាដ៏នក្ខត្តឫក្សនេះ។

*** ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ**

ណែនាំដល់អង្គភាពក្រោមឱវាទឱ្យសហការការពារសន្តិសុខ របៀបរៀបរយ សណ្ដាប់ធ្នាប់សង្គម ចរាចរណ៍ បម្រើឱ្យការរៀបចំព្រះរាជពិធីបុណ្យគ្រងព្រះបរមសិរីរាជសម្បត្តិថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ធានាបានសុវត្ថិភាពល្អប្រសើរ និងចាត់តាំងឱ្យមានការអុជកាំជ្រួច នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥ វេលាម៉ោង ១៩:០០នាទីយប់ ដើម្បីអបអរសាទរព្រះរាជពិធីបុណ្យនេះ។

*** ទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ជួយបង្កលក្ខណៈងាយស្រួលដោះស្រាយសម្ភារៈ ថវិកា ជូនដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រាប់បម្រើឱ្យព្រះរាជពិធីដ៏មានសារសំខាន់នេះ បានសមស្រប និងទាន់ពេលវេលា។

*** គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**

រៀបចំកម្មវិធីចុះសួរសុខទុក្ខបងប្អូនអ្នកជំងឺ ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យនានា និងចាស់ជរាគ្មានទីពឹង ដោយអំពាវនាវគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន អង្គភាព ឱ្យចូលរួមជួយឧបត្ថម្ភអំណោយជាសម្ភារៈ ថវិកា។

គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សង្ឃឹមនិងជឿជាក់ថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត នឹងអនុវត្តនូវផែនការណែនាំនេះ ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥
**ជ. គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**
**ប្រធាន**

**សម្ដេចមហាមន្ត្រី គុយ សុផល**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម ឧបនាយករដ្ឋមន្ត្រីប្រចាំការ "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោកសម្រាប់ប្រើ
# ក្នុងព្រះរាជពិធីបុណ្យខួបលើកទី២១ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ
# ថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ
# នៃព្រះរាជាណាចក្រកម្ពុជា

១. អបអរសាទរខួបលើកទី២១ នៃព្រះរាជពិធីគ្រងព្រះបរមសិរីរាជសម្បត្តិថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា

២. សូមថ្វាយព្រះរាជសព្ទសាធុការពរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា សូមមានព្រះរាជសុខភាពល្អ និងព្រះជន្មាយុយឺនយូរ

៣. ជយោ ! ព្រះរាជាណាចក្រកម្ពុជា

៤. ជាតិ សាសនា ព្រះមហាក្សត្រ

៥. ជយោ ! លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា

៦. ជយោ ! សន្តិភាព និងការបង្រួបបង្រួមជាតិ

៧. ជយោ ! សន្តិភាព និងអភិវឌ្ឍន៍

៨. មានសន្តិភាព ទើបមានការអភិវឌ្ឍប្រទេសជាតិ

៩. ជយោ! សន្តិភាព ដោយនយោបាយ ឈ្នះ ឈ្នះ

១០. ជយោ! នយោបាយ ឈ្នះ ឈ្នះ នាំមកនូវសន្តិភាព

១១. អរគុណសន្តិភាព ក្រោមការដឹកនាំរបស់ **សម្តេចតេជោ ហ៊ុន សែន**

១២. ជយោ! សន្តិភាព ប្រជាធិបតេយ្យ និងការអភិវឌ្ឍ